# របាយការណ៍ប្រចាំឆ្នាំ

## សមិទ្ធផលសំខាន់ៗ

## ២០២១



### មូលនិធិ ម៉េងលី ជេ. គួច

ជាមូលនិធិសប្បុរសធម៌ធំមួយក្នុងប្រទេសកម្ពុជា

+៨៥៥ ៩៥ ៨៨៨ ០៨៤

www.mjqfoundation.org



# មាតិកា៖


មាតិកា ........ -i-

សាររបស់នាយកប្រតិបត្តិ ........ -ii-

ប្រវត្តិរបស់យើង ........ ០១

ទស្សនៈវិស័យ បេសកកម្ម និងគុណតម្លៃ ........ ០២

វឌ្ឍនភាពរបស់មូលនិធិ ម៉េងលី ជេ. គួច ........ ០៣

កម្មវិធីអប់រំ ........ ០៦

គម្រោងអាហារូបករណ៍ ម៉េងលី ជេ. គួច ........ ០៨

គម្រោងបណ្ណាល័យចល័ត ម៉េងលី ជេ. គួច ........ ០៩

គម្រោងគុណភាពសិក្សា និងការបង្រៀន ........ ១០

គម្រោងបណ្ណាល័យចល័ត ម៉េងលី ជេ. គួច ........ ០៩

កម្មវិធីសុខភាព ........ ១១

គម្រោងឆ្លើយតបការសង្គ្រោះបន្ទាន់ផ្នែកសុខភាព ........ ១៣

កម្មវិធីសេវាសហគមន៍ ........ ១៤

គម្រោងឆ្លើយតបការសង្គ្រោះ ........ ១៦

គម្រោងធនាគារអាហារសប្បុរសធម៌ ម៉េងលី ជេ. គួច ........ ១៧

ព័ត៌មានអំពីហិរញ្ញវត្ថុ ........ ១៨

ដៃគូររបស់យើង ........ ១៩

ក្រុមប្រឹក្សាភិបាល ........ ២០

គណៈកម្មការប្រតិបត្តិ ........ ២១

អក្សរកាត់ ........ ២២

ទំនាក់ទំនងពួកយើង ........ ២៣



# សាររបស់អ្នកឧកញ៉ា បណ្ឌិត គួច ម៉េងលី
## នាយកប្រតិបត្តិ នៃអង្គការមូលនិធិ ម៉េងលី ជេ. គួច

ខ្ញុំពិតជាមានក្ដីសោមនស្សរីករាយក្រៃលែងក្នុងការបង្ហាញជូនសាធារណៈជន និងសប្បុរសជនទាំងអស់នូវរបាយការណ៍ប្រចាំឆ្នាំ២០២១របស់អង្គការមូលនិធិ ម៉េងលី ជេ. គួច ដែលនឹងបញ្ចូលនូវព័ត៌មានសំខាន់ៗ និងវឌ្ឍនភាពនានារបស់អង្គការមូលនិធិ ម៉េងលី ជេ. គួច ចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២១។

របាយការណ៍នេះនឹងរៀបរាប់ប្រាប់ពីប្រវត្តិរបស់អង្គការមូលនិធិ ម៉េងលី ជេ. គួច ការរីកចម្រើន និងវឌ្ឍនភាពក្នុងរយៈពេល១២ខែនាឆ្នាំ២០២១ ផែនការសកម្មភាពបន្ត និងមេរៀនបទពិសោធន៍មួយចំនួន ដែលយើងទទួលបានពីការអនុវត្តសកម្មភាពកន្លងមក។ ចេញពីរបាយការណ៍នេះ លោកអ្នកនឹងបានស្គាល់ថា យើងជានរណា? យើងធ្វើការងារអ្វី? និងយើងធ្វើការងារនៅកន្លែងណា?

ខ្ញុំសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា របាយការណ៍នេះនឹងផ្ដល់ព័ត៌មានដល់បុគ្គលិកអង្គការជាតិ និងអន្តរជាតិ ម្ចាស់ជំនួយ ក្រុមហ៊ុន និងសហគ្រិនភាព សម្រាប់ជាមូលដ្ឋានក្នុងការសិក្សាស្រាវជ្រាវ និងការជម្រុញទឹកចិត្តដល់សិស្ស និស្សិតផងដែរ។ ជាងនេះទៅទៀត ខ្ញុំសង្ឃឹមថា របាយការណ៍នេះនឹងបានជូនដំណឹងដល់សាធារណៈជនទាំងឡាយ ឱ្យបង្កើនការយល់ដឹង ការវិភាគ និងការគិតពិចារណាស៊ីជម្រៅលើការងារអភិវឌ្ឍវិស័យអប់រំ សុខភាពសាធារណៈ កិច្ចការសប្បុរសធម៌ និងសង្គម ការអភិវឌ្ឍធនធានមនុស្ស ការអភិវឌ្ឍសហគមន៍ ការឆ្លើយតបសង្គ្រោះបន្ទាន់ និងការឆ្លើយតបគ្រោះមហន្តរាយ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង បុគ្គលិក នៃអង្គការមូលនិធិ ម៉េងលី ជេ. គួច និងបុគ្គលិក នៃក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ទាំងអស់ ដែលតែងតែផ្ដល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងការសហការ ដល់អង្គការមូលនិធិ ម៉េងលី ជេ. គួច ព្រមទាំងការចូលរួមអនុវត្តសកម្មភាពនានាតាំងពីចាប់ផ្ដើមរហូតដល់ពេលបច្ចុប្បន្ន។ ស្របពេលជាមួយគ្នា ខ្ញុំក៏សូមថ្លែងអំណរគុណដល់បណ្ដាម្ចាស់ជំនួយ ក្រុមហ៊ុន និងសប្បុរសជននានា សម្រាប់គាំទ្រជំនួយសប្បុរសធម៌មកកាន់អង្គការមូលនិធិ ម៉េងលី ជេ. គួច ដើម្បីរួមចំណែកកិច្ចការសង្គម និងការងារសប្បុរសធម៌។

ខ្ញុំសូមជូនពរអ្នកទាំងអស់គ្នា សូមបានប្រកបតែនឹងសេចក្ដីសុខ សុខភាពល្អ សុភមង្គល សុខសុវត្ថិភាព និងជោគជ័យក្នុងជីវិត!

ដោយក្ដីស្រឡាញ់ និងរាប់អានពីខ្ញុំបាទ

**អ្នកឧកញ៉ា បណ្ឌិត គួច ម៉េងលី**

# ប្រវត្តិរបស់យើង



វិទ្យាស្ថានកម្ពុជាសម្រាប់សុខភាពកុមារ និងយុវជន ហៅកាត់ថា ស៊ីការ (CICAH) គឺជាមូលនិធិក្នុងស្រុកមួយ ដែលមានគោលដៅក្នុងការផ្តល់នូវរាល់ព័ត៌មាន និង សេវាកម្មនានា ដែលទាក់ទងនឹងបញ្ហាសុខភាពទៅដល់កុមារ យុវជន និងមាតា ដែលជួបការលំបាកនៅក្នុងទីក្រុងភ្នំពេញ និងតាមជនបទដាច់ស្រយាល។ វិទ្យាស្ថានកម្ពុជាសម្រាប់សុខភាពកុមារ និងយុវជន ត្រូវបានបង្កើតឡើងក្រោមគំនិតផ្តួចផ្តើមរបស់ឯកឧត្តម ឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី នៅក្នុងឆ្នាំ២០០៤ ដើម្បីលើកកម្ពស់វិស័យអប់រំក្នុងចំណោមកុមារជាច្រើន ដែលជួបការលំបាក តាមរយៈការផ្តល់អាហារូបករណ៍។

ដើម្បីធានាឱ្យបានសកម្មភាពរបស់ខ្លួនកាន់តែទទួលបានជោគជ័យបន្ថែមទៀតនោះ នៅចុងឆ្នាំ២០១២ ស៊ីការ (CICAH) បានរៀបចំផែនការ និងដាក់ចេញនូវទស្សនវិស័យ គោលបំណង និងបេសកម្មយ៉ាងច្បាស់លាស់បន្ថែមទៀត រហូតដល់ដើមឆ្នាំ២០១៣ ស៊ីការ (CICAH) បានប្តូរឈ្មោះជាផ្លូវការទៅ អង្គការមូលនិធិ ម៉េងលី ជេ. គួច ដែលបានចុះបញ្ជីទទួលស្គាល់ដោយក្រសួងមហាផ្ទៃ ប្រកាសលេខ ៩៧១ ស.ជ.ណ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ ត្រូវបានសរសេរជាភាសាអង់គ្លេស “Mengly J. Quach Foundation Organization”។



## VISION

ទស្សនវិស័យរបស់អង្គការមូលនិធិ ម៉េងលី ជេ.គួច គឺចង់ឃើញប្រជាពលរដ្ឋដែលងាយរងគ្រោះ និងត្រូវបានគេរើសអើងទទួលបាននូវភាពស្មើគ្នាចំពោះសេវាអប់រំ សុខភាព ស្បៀងអាហារ និងតម្រូវការចាំបាច់ជាមូលដ្ឋាននានាដើម្បីឲ្យពួកគេរស់នៅក្នុងភាពល្អប្រសើរ និងមានភាពថ្លៃថ្នូរជាមនុស្សជាតិ នៅក្នុងរាជរដ្ឋាភិបាល កម្ពុជា។

## MISSION

អង្គការមូលនិធិ ម៉េងលី ជេ. គួច កំពុងរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជាប្រកបដោយសន្តិភាព និងភាពសុខដុមរម្យនា តាមរយៈការផ្តល់នូវតម្រូវការចាំបាច់ជាមូលដ្ឋាន និងឱកាសដល់ប្រជាជន ដែល ងាយរងគ្រោះ និងត្រូវបានគេរើសអើង។

## VALUES

- សាមគ្គភាព
- ប្តេជ្ញាធ្វើការជាមួយជនក្រីក្រ
- សន្សំសំចៃខ្ពស់
- មានទំនួលខុសត្រូវខ្ពស់

# វឌ្ឍនភាពរបស់យើង



២០០៤

- វិទ្យាស្ថានកម្ពុជាសម្រាប់សុខភាពកុមារ និងយុវជន ហៅកាត់ថា ស៊ីកា (CICAH) ត្រូវបានបង្កើតឡើង
- CICAH បានសាងសង់អណ្តូងទឹកមួយនៅឃុំដំរីផុង ស្រុកឆ្លូង ខេត្តក្រចេះ

២០០៦



- CICAH សម្ពោធគម្រោងបណ្ណាល័យចល័ត ម៉េងលី ជេ. គួច នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០០៦ ដោយបានបរិច្ចាគសម្ភារសិក្សាដល់វិទ្យាល័យបាក់ទូក ក្នុងរាជធានីភ្នំពេញ
- CICAH សម្ពោធគម្រោងសាងសង់សាលារដ្ឋ ម៉េងលី ជេ. គួច នៅថ្ងៃទី៥ ខែសីហា ឆ្នាំ ២០០៦



២០០៧

- ជួសជុលអគារសាលារដ្ឋ១ខ្នង មាន៤បន្ទប់ នៅសាលាបឋមសិក្សា ថ្នក់ង្កែប គួច ប៉េងសាំង ងិនហួយ ស្ថិតនៅភូមិកង្កែប ឃុំប្រឡូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង
- CICAH បានបរិច្ចាគថវិកាចំនួន៥,០០០ ដុល្លារដល់កាកបាទក្រហមកម្ពុជា

២០០៨



- សាងសង់អគារសាលារដ្ឋ ១ខ្នង មាន៤បន្ទប់ នៅសាលាបឋមសិក្សា ថ្នក់ង្កែប គួច ប៉េងសាំង ងិនហួយ ស្ថិតនៅភូមិកង្កែប ឃុំប្រឡូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង
- CICAH សម្ពោធគម្រោងធនាគារអាហារ សប្បុរសធម៌ ម៉េងលី ជេ. គួច នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨



២០០៩

- CICAH សម្ពោធគម្រោងគ្លីនិកព្យាបាលចល័ត វេជ្ជបណ្ឌិត គួច នៅថ្ងៃទី១៤ ខែមេសា ឆ្នាំ ២០០៩ ដោយបានបរិច្ចាគជំនួយសង្គ្រោះបឋម និងថ្នាំពេទ្យដល់ប្រជាពលរដ្ឋរងគ្រោះក្នុងខេត្តរតនៈគិរី

២០១០



- CICAH បានបរិច្ចាគអង្ករចំនួន៤,០០០គ.កដល់ប្រជាពលរដ្ឋក្រីក្រចំនួន១៦០ គ្រួសារក្នុងឃុំជាំសង្កែ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ
- ផ្លូវចំនួន១ខ្សែត្រូវបានសាងសង់ក្នុងឃុំជាំសង្កែ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ
- CICAH បរិច្ចាគកង់ សម្ភារសិក្សា កុំព្យូទ័រ ម៉ាស៊ីនព្រីន កាមេរ៉ា ម៉ាស៊ីនភ្លើង និងកៅអីសិស្សដល់សាលាបឋមសិក្សា ថ្នក់ង្កែប គួច ប៉េងសាំង ងិនហួយ ស្ថិតនៅភូមិកង្កែប ឃុំប្រឡូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង
- CICAH សម្ពោធគម្រោងទេព្យកោសលដើម្បីជំនួយឧបត្ថម្ភ



២០១១

- CICAH បរិច្ចាគអង្ករចំនួន១០,០០០គ.ក ដល់អង្គការកុមារកំព្រាក្នុងខេត្តកំពង់ស្ពឺ
- CICAH បរិច្ចាគអង្ករ ត្រីខកំប៉ុង ទឹកស៊ីអ៊ីវ មីកញ្ចប់ ថ្នាំពេទ្យ និងថវិកា ដល់ប្រជាពលរដ្ឋចំនួន២,៩៨៨គ្រួសារ ដែលរងគ្រោះដោយសារទឹកជំនន់ក្នុងខេត្តកណ្ដាល កំពង់ឆ្នាំង និងបាត់ដំបង
- CICAH បរិច្ចាគកុំព្យូទ័រចំនួន២គ្រឿង និងម៉ាស៊ីនព្រីនចំនួន១គ្រឿង ដល់សាលាស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង
- CICAH បរិច្ចាគទូរសព្ទចល័តចំនួន១២គ្រឿងដល់អាជ្ញាធរស្រុកកោះខែល ខេត្តកណ្ដាល

## ២០១២



- CICAH បរិច្ចាគអង្ករចំនួន៧,៥០០គ.ក ដល់អង្គការកុមារកំព្រាក្នុងខេត្តកំពង់ស្ពឺ
- CICAH សម្ពោធគម្រោងឆ្លើយតបសង្គ្រោះបន្ទាន់សុខភាព នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១២

## ២០១៣



- វិទ្យាស្ថានកម្ពុជាសម្រាប់សុខភាពកុមារ និងយុវជន ហៅកាត់ថា ស៊ីការ (CICAH) ត្រូវបានប្តូរឈ្មោះជាផ្លូវការទៅជា អង្គការមូលនិធិ ម៉េងលី ជេ. គួច ប្រកាសលេខ ៩៧១ ស.ជ.ណ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៣
- គម្រោង ធនាគារឈាម ម៉េងលី ជេ. គួច ត្រូវបានសម្ពោធដំណើរការនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣
- មូលនិធិ ម៉េងលី ជេ. គួច សាងសង់ស្ពានថ្មប្រវែង១៨ម៉ែត្រ បង្គន់អនាម័យចំនួ១៣ និង អណ្តូងទឹកចំនួន៣ ក្នុងខេត្តព្រៃវែង និងខេត្តតាកែវ។
- មូលនិធិ ម៉េងលី ជេ. គួច បរិច្ចាគអង្ករ ត្រីខកំប៉ុង ទឹកស៊ីអុីវ មីកញ្ចប់ ថ្នាំពេទ្យ និងថវិកា ដល់ប្រជាពលរដ្ឋចំនួន២,៩៨៨គ្រួសារ ដែលរងគ្រោះដោយសារទឹកជំនន់ក្នុងខេត្ត កណ្តាល កំពង់ចាម ព្រៃវែង និងកំពង់ស្ពឺ

## ២០១៤



- មូលនិធិ ម៉េងលី ជេ. គួច សម្ពោធដំណើរការកម្មវិធីរត់ដើម្បីសប្បុរសធម៌ នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤
- មូលនិធិ ម៉េងលី ជេ. គួច សម្ពោធដំណើរការគម្រោងអាហារូបករណ៍ ម៉េងលី ជេ. គួច នៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៤

## ២០១៥



- មូលនិធិ ម៉េងលី ជេ. គួច បរិច្ចាគថវិកាចំនួន ១១,៥៩៨,៨០០រៀល និង៥២៦ដុល្លារជួយប្រជាជននេប៉ាល់ ដែលរងគ្រោះដោយសាររញ្ជួយដី នាថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៥
- មូលនិធិ ម៉េងលី ជេ. គួច បានបរិច្ចាគថវិកាចំនួន ៦,៩០៧,៥០០រៀលដល់មន្ទីរពេទ្យគន្ធបុប្ផា ក្នុងរាជធានីភ្នំពេញ

## ២០១៦



- សាងសង់អគារសាលារដ្ឋ១ខ្នង ២ជាន់ មាន៤បន្ទប់ នៅសាលាបឋមសិក្សា គួច ម៉េងលី ទួលបេង ស្ថិតនៅភូមិទួលបេង ឃុំក្រឡា ស្រុកកំពង់សៀម ខេត្តកំពង់ចាម
- មូលនិធិ ម៉េងលី ជេ. គួច បានបរិច្ចាគគ្រែពេទ្យចំនួន១៣៨គ្រឿង ដល់មន្ទីរពេទ្យរដ្ឋ ក្នុងរាជធានីភ្នំពេញ

## ២០១៧



- គម្រោងកង់សម្រាប់ការអប់រំកុមារ ត្រូវបានសម្ពោធដំណើរការនៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៧ ដោយបានបរិច្ចាគកង់ចំនួន២៣៨គ្រឿងដល់សិស្សក្រីក្រ
- មូលនិធិ ម៉េងលី ជេ. គួច បានបរិច្ចាគ LCD ចំនួន១គ្រឿង Laptop ចំនួន១គ្រឿង កាមេរ៉ាចំនួន១គ្រឿង និងកៅអីសិស្សចំនួន៥០ ដល់សាលាបឋមសិក្សាអរិយកស្សប ស្ថិត
- មូលនិធិ ម៉េងលី ជេ. គួច សាងសង់បន្ទប់សិក្សាសហគមន៍ចំនួន១ទំហំ ៤.៥ម៉ x ៧ម៉ នោងបរិច្ចាគកៅអីចំនួន៥០ ដល់សាលាសហគមន៍ ស្ថិតក្នុងឃុំអរាង ស្រុកកំពង់សៀម ខេត្តកំពង់ចាម

២០១៨



- មូលនិធិ ម៉េងលី ជេ. គួច បានសាងសង់សាលាឆាន់ចំនួនមួយខ្នងស្ថិតនៅវត្តគិរីសេត្ថារាម ក្នុងឃុំច្រណូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង
- មូលនិធិ ម៉េងលី ជេ. គួច បរិច្ចាគកង់ចំនួន២០៣គ្រឿងដល់សិស្សក្រីក្រចំនួន២០៣ នៅខេត្តកំពង់ឆ្នាំង និងខេត្តកណ្តាល
- គម្រោងធនាគារអាហារសប្បុរសធម៌ ម៉េងលី ជេ. គួច លើកទី១៩៣ ដោយបរិច្ចាគអង្ករចំនួន១២,០០០គ.ក គ្រឿងឧបភោគបរិភោគ និងថវិកាដល់គ្រួសារក្រីក្រចំនួន២៤៥ នៅស្រុកកៀនស្វាយ ខេត្តកណ្តាល
- មូលនិធិ ម៉េងលី ជេ. គួច បានសាងសង់អណ្តូងទឹកស្អាតចំនួន១ស្ថិតនៅក្នុងមណ្ឌលសុខភាពដំរីផុង ឃុំដំរីផុង ស្រុកឆ្លូង ខេត្តក្រចេះ
- មូលនិធិ ម៉េងលី ជេ. គួច បានធ្វើសវនកម្មខាងក្រៅ ដោយក្រុមហ៊ុនសវនកម្មឯករាជ្យ

២០១៩

- មូលនិធិ ម៉េងលី ជេ. គួច បានចូលជាសមាជិកពេញសិទ្ធជាមួយអង្គការ CCC
- មូលនិធិ ម៉េងលី ជេ. គួច បានបរិច្ចាគកង់ចំនួន៨៥គ្រឿងដល់សិស្សក្រីក្រក្នុងរាជធានីភ្នំពេញ
- គម្រោងធនាគារអាហារសប្បុរសធម៌ ម៉េងលី ជេ. គួច លើកទី២០០ ដោយបានបរិច្ចាគអង្ករចំនួន១៥,០០០គ.ក គ្រឿងឧបភោគបរិភោគ និងថវិកា ដល់គ្រួសារក្រីក្រចំនួន៣០០គ្រួសារ នៅខណ្ឌសែនសុខ
- មូលនិធិ ម៉េងលី ជេ. គួច បានបរិច្ចាគមីកញ្ចប់ចំនួន៣០០កេស និងអាវរងារចំនួន៣០០អាវ ដល់កងទ័ពការពារព្រំដែននៅប្រាសាទព្រះវិហារ
- មូលនិធិ ម៉េងលី ជេ. គួច បរិច្ចាគថវិកាចំនួន១០,០០០ដុល្លារដល់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីជួយគ្រួសាររងគ្រោះដោយការបាក់រលំអគារនៅខេត្តព្រះសីហនុ
- គម្រោងសិក្ខាសាលាសប្បុរសធម៌ ឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី ត្រូវបានចាប់ផ្តើមដំបូងនៅថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៩

២០២០



- មូលនិធិ ម៉េងលី ជេ. គួច បានសាងសង់អណ្តូងទឹកស្អាតចំនួន១ស្ថិតនៅក្នុងឃុំច្រណូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង
- មូលនិធិ ម៉េងលី ជេ. គួបរិច្ចាគថវិកាចំនួន១០,០០០ដុល្លារដល់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីជួយគ្រួសាររងគ្រោះដោយសារការបាក់រលំអគារនៅខេត្តកែប
- មូលនិធិ ម៉េងលី ជេ. គួបរិច្ចាគថវិកាចំនួន១០០,០០០,០០០រៀលដល់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីជួយគ្រួសាររងគ្រោះដោយសារគ្រោះទឹកជំនន់ ក្នុងខែតុលា ឆ្នាំ២០២០
- មូលនិធិ ម៉េងលី ជេ. គួបរិច្ចាគថវិកាចំនួន១០,០០០ដុល្លារដល់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីជួយរដ្ឋាភិបាលកម្ពុជាទិញវ៉ាក់សាំងកូវីដ-១៩

២០២១



- មូលនិធិ ម៉េងលី ជេ. គួច សាងសង់ផ្ទះចំនួន១ខ្នងជូនដល់គ្រួសារក្រីក្រចំនួន១គ្រួសារ ឈ្មោះ ឱត សារី រស់នៅខណ្ឌសែនសុខ រាជធានីភ្នំពេញ
- មូលនិធិ ម៉េងលី ជេ. គួច បានបរិច្ចាគគ្រឿងឧបភោគបរិភោគដល់ប្រជាពលរដ្ឋក្រីក្រចំនួន១,៥១៣គ្រួសារ ក្រោមគម្រោងធនាគារអាហារសប្បុរសធម៌ ម៉េងលី ជេ. គួច ឆ្នាំ២០២១
- មូលនិធិ ម៉េងលី ជេ. គួច បរិច្ចាគថវិកាចំនួន១០,៣០០ដុល្លារដល់គ្រួសារខ្វះខាតមួយ គឺលោកតា ងិន ម៉េង ដើម្បីសាងសង់ផ្ទះរស់នៅក្នុងស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង



# កម្មវិធីអប់រំ

អង្គការមូលនិធិ ម៉េងលី ជេ. គួច បានចូលរួមយ៉ាងសកម្មក្នុងការលើកកម្ពស់ការអប់រំនៅទូទាំងប្រទេសកម្ពុជា និងបានកំពុងបន្តបេសកកម្មរបស់ខ្លួនក្នុងការកសាងសង្គម និងសហគមន៍ងាយរងគ្រោះនៅក្នុងប្រទេសកម្ពុជា។ យើងចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍ និងគ្រប់គ្រងសាលារៀនក្នុងភាពជាដៃគូជាមួយរដ្ឋាភិបាល តាមរយៈការផ្តល់ការអប់រំប្រកបដោយគុណភាពខ្ពស់ដល់យុវជនរាប់ពាន់នាក់ និងគាំទ្រដល់អ្នកដឹកនាំនាពេលអនាគត ដែលមានសក្តានុពល។ គោលដៅ នៃកម្មវិធីអប់រំ គឺធ្វើឱ្យប្រសើរឡើងនូវបរិក្ខាសិក្សា ហេដ្ឋារចនាសម្ព័ន្ធ និងបរិយាកាសសាលារៀន ដើម្បីធានាឱ្យមានបរិយាកាសអប់រំប្រកបដោយសុវត្ថិភាព និងផាសុកភាពសម្រាប់សិស្សានុសិស្សនៃសាលាបឋមសិក្សា អនុវិទ្យាល័យ និងថ្នាក់វិទ្យាល័យ។

អង្គការមូលនិធិ ម៉េងលី ជេ. គួច បានកំពុងអនុវត្តគម្រោងចំនួន៦ នៃកម្មវិធីអប់រំ ដូចមានខាងក្រោម៖

- ✓ គម្រោង កង់ដើម្បីការអប់រំកុមារ
- ✓ គម្រោង សាងសង់សាលារដ្ឋ ម៉េងលី ជេ. គួច
- ✓ គម្រោង អាហារូបករណ៍ ម៉េងលី ជេ. គួច
- ✓ គម្រោង បណ្ណាល័យចល័ត ម៉េងលី ជេ. គួច
- ✓ គម្រោង គុណភាពបង្រៀន និងការសិក្សា
- ✓ គម្រោងសិក្ខាសាលាសប្បុរសធម៌ឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី

# សមិទ្ធផលអាទិភាព
## ខែមករា-ខែធ្នូ ឆ្នាំ២០២១

**១,០០៥នាក់** សិស្ស និងនិស្សិត ទទួលបានការគាំទ្រ ហិរញ្ញវត្ថុ និងសម្ភារសិក្សា ក្រោមកម្មវិធី អប់រំ៖

**១៥នាក់** និស្សិតថ្មីត្រូវបានជ្រើសរើសជោគជ័យ ដើម្បីទទួលអាហារូបករណ៍ ម៉េងលី ជេ. គួច សិក្សាថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ នៅតាមសាកលវិទ្យាល័យល្បីៗ ក្នុងរាជធានីភ្នំពេញ និងខេត្ត នានា។ រហូតមកដល់បច្ចុប្បន្ន សិស្ស និងនិស្សិតសរុបចំនួន ៦៤នាក់ បានទទួលអាហារូបករណ៍ពីមូលនិធិ ម៉េងលី ជេ. គួច។

**៣១០នាក់** សិស្សានុសិស្ស ទទួលជំនួយសម្ភារសិក្សាក្នុងកម្មវិធី បណ្ណាល័យចល័តលើកទី៦៦ និង៦៧ របស់អង្គការមូលនិធិម៉េងលី ជេ. គួច ក្នុងឆ្នាំ២០២១

**៦៨០នាក់** សិស្សានុសិស្ស និងលោកគ្រូអ្នកគ្រូ ទទួលជំនួយសម្ភារសិក្សា និង សម្ភារបង្រៀន ក្នុងកម្មវិធីផ្តល់ជំនួយសប្បុរសធម៌របស់ អង្គការ មូលនិធិម៉េងលី ជេ. គួច ក្នុងឆ្នាំ២០២១



# គម្រោង

## គម្រោង អាហារូបករណ៍ ម៉េងលី ជេ. គួច

គម្រោងអាហារូបករណ៍ ម៉េងលី ជេ. គួច ត្រូវបានផ្តួចផ្តើមគំនិតឡើងដោយលោកឧកញ៉ា វេជ្ជបណ្ឌិត គួចម៉េងលី នាយកប្រតិបត្តិ នៃអង្គការមូលនិធិ ម៉េងលី ជេ. គួច នៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៤។ គម្រោងនេះផ្តោតសំខាន់គឺជួយគាំទ្រហិរញ្ញវត្ថុដល់សិស្ស និស្សិត ដែលខ្វះលទ្ធភាពសិក្សានៅថ្នាក់ឧត្តមសិក្សា ដែលភាគច្រើននិស្សិតជាក្មេងកំព្រា ឬក្រីក្រមកពីជនបទដាច់ស្រយាលជាដើម។ ចាប់តាំងពីគម្រោងចាប់ផ្តើមមក មូលនិធិ ម៉េងលី ជេ. គួច បានផ្តល់ហិរញ្ញវត្ថុចំនួន១៣៣,៧៥៣ដុល្លារ ដល់និស្សិតអាហារូបករណ៍ចំនួន៦៥នាក់។

**សង្ខេបសមិទ្ធផល ២០២១**

**១៥នាក់**
សិស្ស និងនិស្សិតថ្មីត្រូវបានជ្រើសរើសជោគជ័យ ដើម្បីទទួលអាហារូបករណ៍ ម៉េងលី ជេ. គួច

**៣នាក់**
បានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ ដោយជោគជ័យ

- *និស្សិតចំនួន១៤នាក់ ទទួលអាហារូបករណ៍ សិក្សាថ្នាក់បរិញ្ញាបត្រនៅសាកលវិទ្យាល័យក្នុងឆ្នាំសិក្សា២០២១*
- *សិស្សម្នាក់ ទទួលអាហារូបករណ៍សិក្សាពីថ្នាក់មត្តេយ្យរហូតដល់ថ្នាក់ទី១២*
- *និស្សិតចំនួន១០ទទួលបានការងារហាត់ការក្នុងក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន*
- *និស្សិតចំនួន៥នាក់ទទួលបានការស្នាក់នៅ និងអាហារហូបចុកជាមួយបុគ្គលិកអ្នកផ្ទះ*





# គម្រោង បណ្ណាល័យចល័ត ម៉េងលី ជេ. គួច

គម្រោងបណ្ណាល័យចល័ត ម៉េងលី ជេ. គួច ត្រូវបានផ្តួចផ្តើមបង្កើតឡើង នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៦។ គម្រោងនេះមានគោលបំណងបង្កើតលទ្ធភាព និងឱកាសដល់សិស្សានុសិស្ស ក៏ដូចជាកុមារតាមសហគមន៍អាចចូលរួមសកម្មភាពសិក្សាក្រៅម៉ោងសិក្សាក្នុងសាលារដ្ឋដូចជា ការអានសៀវភៅ ការនិទានរឿង ការគូររូបគំនូរជាដើម។ ក្រៅពីការធ្វើសកម្មភាពខាងលើ គម្រោងបណ្ណាល័យចល័ត ម៉េងលី ជេ. គួច ក៏បានធ្វើសកម្មភាពបរិច្ចាគជាសម្ភារសិក្សាជូនដល់សិស្ស និងបរិច្ចាគជាសម្ភារបង្រៀនសម្រាប់ដាក់នៅក្នុងបណ្ណាល័យក្នុងសាលារៀន បណ្ណាល័យសហគមន៍ និងអង្គការ សមាគមនានាផងដែរ។ រហូតមកដល់ពេលនេះ មូលនិធិម៉េងលី ជេ. គួច បានធ្វើសកម្មភាពគម្រោង បណ្ណាល័យចល័ត ម៉េងលី ជេ. គួច បានចំនួន៦៧លើក ដោយមានកុមារទទួលផលសរុបចំនួន១៥,៤២១នាក់ ក្នុងរាជធានីភ្នំពេញ និងតាមបណ្តាខេត្តគោលដៅរបស់មូលនិធិ ម៉េងលី ជេ. គួច ដោយ៖

- *ផ្តល់សម្ភារសិក្សា ដូចជា កាបូបសិស្ស សៀវភៅសរសេរ ប៊ិក ខ្មៅដៃ បន្ទាត់*
- *ផ្តល់សៀវភៅអានដល់បណ្ណាល័យតាមសាលា អង្គការ និងស្ថាប័ននានា*
- *រៀបចំកម្មវិធីបណ្ណាល័យចល័តបានសរុបចំនួន៦៧លើក ដល់សិស្សានុសិស្ស និងកុមារតូចៗ*
- *សាងសង់ និងជួសជុលបណ្ណាល័យតាមសាលាខ្សត់ខ្សោយនានា។*

**សង្ខេប សមិទ្ធផល ២០២១**

**៣១០ នាក់** សិស្សានុសិស្ស ទទួលជំនួយសម្ភារសិក្សាក្នុងកម្មវិធីបណ្ណាល័យចល័តលើកទី៦៦ និង៦៧ របស់អង្គការ មូលនិធិ ម៉េងលី ជេ. គួច ក្នុងឆ្នាំ២០២១

# គម្រោង គុណភាពបង្រៀន និងការសិក្សា

គម្រោងគុណភាពនៃការបង្រៀន និងការសិក្សាគឺជាគម្រោងអប់រំថ្មីមួយក្នុងចំណោមគម្រោងអប់រំថ្មីចំនួន៦ ដែលត្រូវបានរចនាឡើងដោយក្រុមការងាររបស់អង្គការមូលនិធិម៉េងលី ជេ. គួច កាលពីដើមឆ្នាំ២០១៩ និងត្រូវបានអនុម័តជាផ្លូវការដោយលោកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី នាយកប្រតិបត្តិនៃអង្គការមូលនិធិ ម៉េងលី ជេ. គួច នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៩។ គម្រោងនេះមានគោលបំណងដើម្បីលើកទឹកចិត្តសិស្សានុសិស្ស និងកុមារនៅក្នុងសហគមន៍ឱ្យមានចិត្តចង់រៀន និងដើម្បីលើកកម្ពស់ ប្រព័ន្ធអប់រំនៅកម្ពុជាធ្វើឱ្យប្រសើរឡើង។

ចាប់តាំងពីការបង្កើតគម្រោងនេះ អង្គការមូលនិធិម៉េងលី ជេ. គួច បានធ្វើសកម្មភាពគម្រោងនេះដូចជាការផ្តល់កុំព្យូទ័រ ម៉ាស៊ីនបញ្ចាំង LCD ក្តារព័ត៌មាន កៅអីសិក្សា ឯកសណ្ឋានសិស្ស សម្ភារៈបង្រៀន សម្ភារៈការិយាល័យ សាងសង់បង្គន់អនាម័យ អណ្តូងទឹក អាងស្តុកទឹក សួនផ្កានៅក្នុងសាលារៀនជាដើម ស្ថិតនៅក្នុងខេត្តកំពង់ចាម កំពង់ឆ្នាំង ពោធិសាត់ ព្រៃវែង ក្រចេះ កំពង់ធំ និងភ្នំពេញ។

## សង្ខេប សមិទ្ធផល ២០២១

- *សិស្សានុសិស្សចំនួន៤០០នាក់ នៅសាលាបឋមសិក្សា គួច ម៉េងលី ទួលបេង ទទួលបានតុចំនួន២០ និងកៅអីសិស្សចំនួន៤០*
- *សិស្សានុសិស្សចំនួន២៥០នាក់ នៅសាលាបឋមសិក្សាភូមិ៧ ទទួលបានសម្ភារសិក្សាចំនួន២៥០កញ្ចប់*
- *សិស្សានុសិស្សចំនួន៤០ទទួលបានអត្ថប្រយោជន៍ពីការផ្តល់ហិរញ្ញវត្ថុគាំទ្រដល់កម្មវិធី "computers of change campaign"*



# កម្មវិធីសុខភាព

អង្គការមូលនិធិ ម៉េងលី ជេ. គួច ជួយលើកកម្ពស់ជីវភាពរស់នៅប្រកបដោយសុខភាពល្អនៅក្នុងសហគមន៍នានានៅទូទាំងប្រទេសកម្ពុជា។ អង្គការមូលនិធិ ម៉េងលី ជេ. គួច បានកំពុងធ្វើការផ្សារភ្ជាប់គំនិតផ្តួចផ្តើមផ្នែកសុខភាពដើម្បីធានាថាសិស្ស និស្សិត កុមារកំព្រា ចាស់ជរា ដែលយើងគាំទ្រមានសុខភាពល្អ ដើម្បីបន្តការសិក្សានិងការចិញ្ចឹមជីវិតរបស់ពួកគេ។ អង្គការមូលនិធិ ម៉េងលី ជេ. គួច នឹងបន្តសកម្មភាពគាំទ្រផ្នែកសុខភាព តាមរយៈការផ្តល់សេវាសុខភាពដល់សហគមន៍នានានៅពេលចាំបាច់។ គោលដៅចំបង នៃកម្មវិធីសុខភាព គឺចូលរួមធ្វើឱ្យប្រសើរឡើងនូវមូលដ្ឋានសុខាភិបាលសម្រាប់ពង្រឹងគុណភាពសេវាកម្មសុខភាព និងលទ្ធភាពទទួលបានរបស់គ្រួសារ និងសហគមន៍ងាយរងគ្រោះ។

អង្គការមូលនិធិ ម៉េងលី ជេ. គួច បានកំពុងអនុវត្តគម្រោងចំនួន ៥ នៃកម្មវិធីសុខភាព ដូចមានបង្ហាញក្នុងព័ត៌មានខាងក្រោម៖

- ✓ គម្រោង ឆ្លើយតបសង្គ្រោះបន្ទាន់សុខភាព
- ✓ គម្រោង ធនាគារឈាម ម៉េងលី ជេ. គួច
- ✓ គម្រោង គ្លីនិកព្យាបាលចល័ត វេជ្ជបណ្ឌិត គួច
- ✓ គម្រោង សាងសង់ហេដ្ឋារចនាសម្ព័ន្ធសុខភាព
- ✓ គម្រោង ថៃទាំចាស់ជរា ម៉េងលី ជេ. គួច





# សមិទ្ធផលអាទិភាព

## ខែមករា-ខែធ្នូ ឆ្នាំ២០២១

**៤,៧៧៤នាក់**
អ្នកជំងឺ នៃកម្មវិធីសុខភាព បានទទួលជំនួយហិរញ្ញវត្ថុ សេវាកម្មពិនិត្យសុខភាព និងការព្យាបាលជំងឺ៖

**៦៤នាក់** អ្នកជំងឺ ទទួលបានជំនួយសង្គ្រោះបន្ទាន់សុខភាព និងការព្យាបាលជំងឺ ក្រោមកិច្ចការសម្របសម្រួលរបស់អង្គការមូលនិធិ ម៉េងលី ជេ. គួច

**៦២៧នាក់** អ្នកជំងឺ ទទួលជំនួយគាំទ្រជាថវិកា និងការពិនិត្យព្យាបាលជំងឺពីអ្នកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី ផ្ទាល់ ដែលអ្នកឧកញ៉ាតែងទទួលការណាត់ជួបជាមួយអ្នកជំងឺ ចាប់ពីម៉ោង៤ដល់ម៉ោង១០យប់ ដើម្បីផ្តល់ការពិនិត្យ ពិគ្រោះជំងឺ និងផ្តល់ថវិកាឧបត្ថម្ភជូនជាពិសេសអ្នកជំងឺដែលក្រីក្រខ្លាំង

**៤,០៨២នាក់** អ្នកជំងឺ ទទួលជំនួយគាំទ្រជាថវិកា និងការពិនិត្យព្យាបាលជំងឺពីមជ្ឈមណ្ឌលសុខភាពសិស្ស ម៉េងលី ជេ. គួច

# គម្រោង

## គម្រោង ឆ្លើយតបសង្គ្រោះបន្ទាន់សុខភាព

អង្គការមូលនិធិ ម៉េងលី ជេ. គួច ចាប់ផ្តើមគម្រោងឆ្លើយតបសង្គ្រោះបន្ទាន់ផ្នែកសុខភាព លើកទី១ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១២។ គម្រោងនេះមានគោលបំណង ជួយលើកកម្ពស់របៀបរស់នៅប្រកបដោយសុខភាពល្អនៅក្នុងសហគមន៍មួយចំនួននៅទូទាំងប្រទេសកម្ពុជា។ អង្គការមូលនិធិ ម៉េងលី ជេ. គួច បានកំពុងធ្វើសកម្មភាពដោយផ្សារភ្ជាប់គំនិតផ្តួចផ្តើមផ្នែកសុខភាពដើម្បីធានាថានិស្សិតក្រីក្រ ស្រ្តី ចាស់ជរា កុមារកំព្រារ និងជនទីទ័លក្រមានភាពងាយរងគ្រោះខ្លាំងជាងគេ ទទួលបានជំនួយឧបត្ថម្ភសម្រាប់ការព្យាបាលជំងឺ និងការថែទាំងសុខភាពបានល្អប្រសើរ។ នាពេលកន្លងមកនេះ អង្គការមូលនិធិ ម៉េងលី ជេ. គួច បានចូលរួមយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការឆ្លើយតបសង្គ្រោះបន្ទាន់ផ្នែកសុខភាព ដែលក្នុងនោះអង្គការមូលនិធិ ម៉េងលី ជេ. គួច បានផ្តល់ការគាំទ្រក្នុងការព្យាបាលអ្នកជំងឺប្រមាណជាង ៣៨៥,៧៦៨នាក់ ដូចជាអ្នកជំមហារីសុដន់ អ្នកជំងឺបេះដូង អ្នកជំងឺពកក អ្នកជំងឺផ្នែករោគស្រ្តី អ្នកគ្រោះថ្នាក់ចរាចរណ៍ជាដើម។

**សង្ខេប សមិទ្ធផល ២០២១**

**៤,៧៦៥ នាក់** អ្នកជំងឺ ទទួលជំនួយគាំទ្រជាថវិកា សម្រាប់ការព្យាបាលជំងឺរបស់ពួកគេ និងការទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃ

**៥ នាក់** អ្នកជំងឺ ទទួលជំនួយគាំទ្រជាថវិកា សម្រាប់ការវះកាត់ដោយសារគ្រោះថ្នាក់ចរាចរណ៍ និងជំងឺកម្រិតធ្ងន់

**៤ នាក់** អ្នកជំងឺមហារីក ទទួលជំនួយគាំទ្រជាថវិកា សម្រាប់ការព្យាបាលជំងឺរបស់ពួកគេ និងការទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃ



# កម្មវិធីសេវាសហគមន៍

ប្រជាជន និងសហគមន៍ងាយរងគ្រោះត្រូវទទួលបានការការពារ និងការយកចិត្តទុកដាក់ តាមរយៈសកម្មភាពអភិវឌ្ឍសហគមន៍របស់ពួកគេ និងធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធសហគមន៍ផងដែរ។ កម្មវិធីសេវាសហគមន៍ត្រូវបានរៀបចំឡើងសម្រាប់ការអភិវឌ្ឍ និងការថែរក្សានិរន្តរភាពសហគមន៍នៅកម្ពុជាប្រកបដោយចីរភាព។ កម្មវិធីនេះមានគោលបំណងចូលរួមចំណែកក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធសហគមន៍ ដូចជា អណ្តូងទឹកស្អាត ផ្លូវថ្នល់ ស្ពាន ស្រះទឹកសហគមន៍ បន្ទប់ទឹក សំណង់សាធារណៈក្នុងសហគមន៍ និងការផ្តល់ការគាំទ្រចាំបាច់ដូចជាគ្រឿងឧបភោគ បរិភោគ សម្លៀកបំពាក់ និងរបស់របរប្រើប្រាស់បាច់នានាដល់ប្រជាជនងាយរងគ្រោះនៅតាមសហគមន៍ទូទាំងប្រទេសកម្ពុជា។

អង្គការមូលនិធិ ម៉េងលី ជេ. គួច បានកំពុងអនុវត្តគម្រោងចំនួន ៦ នៃកម្មវិធីសេវាសហគមន៍ ដូចមានបង្ហាញក្នុងព័ត៌មានខាងក្រោម៖

- ✓ គម្រោង ឆ្លើយតបសង្គ្រោះបន្ទាន់
- ✓ គម្រោង ធនាគារអាហារសប្បុរសធម៌ ម៉េងលី ជេ. គួច
- ✓ គម្រោង អំណោយសប្បុរសធម៌
- ✓ គម្រោង គំនិតផ្តួចផ្តើមអាជីវកម្មវៃឆ្លាត
- ✓ គម្រោង សាងសង់ហេដ្ឋារចនាសម្ព័ន្ធសហគមន៍
- ✓ គម្រោង ពានរង្វាន់ ម៉េងលី ជេ. គួច








# សមិទ្ធផលអាទិភាព

## ខែមករា-ខែធ្នូ ឆ្នាំ២០២១

**១,៩២៣នាក់**

អ្នកជំងឺ នៃកម្មវិធីសេវាសហគមន៍ បានទទួលជំនួយហិរញ្ញវត្ថុ និងសម្ភារសម្រាប់ទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃ៖

**១,៥១៣ នាក់** អ្នកទទួលផល នៃគម្រោងធនាគារអាហារសប្បុរសធម៌ ម៉េងលី ជេ. គួច ទទួលគ្រឿងឧបភោគ បរិភោគ សម្រាប់ទ្រទ្រង់ជីវភាពរបស់នៅរបស់ពួកគេ

**២៩៤ នាក់** អ្នកទទួលផល នៃគម្រោងអំណោយសប្បុរសធម៌ ទទួលអំណោយជាសម្ភារប្រើប្រាស់ចាំបាច់ ដូចជាគ្រឿងសង្ហារឹម ពូក តុ និងសម្ភារផ្ទះបាយ

**១០៦ នាក់** អ្នកទទួលផល នៃគម្រោងឆ្លើយតបសង្គ្រោះបន្ទាន់ ទទួលការឧបត្ថម្ភថវិកា និងសម្ភារសម្រាប់ទ្រទ្រង់ជីវភាពរបស់នៅរបស់ពួកគេ

**១០ នាក់** អ្នកទទួលផល នៃគម្រោងឆ្លើយតបសង្គ្រោះបន្ទាន់ ជាស្ត្រីមេម៉ាយ ចាស់ជរា ជនពិការ ទទួលការឧបត្ថម្ភថវិកាប្រចាំខែសម្រាប់ទ្រទ្រង់ជីវភាពរបស់នៅរបស់ពួកគេ

# គម្រោង

## គម្រោង ឆ្លើយតបសង្គ្រោះបន្ទាន់

ដើមឡើយគម្រោងនេះមានឈ្មោះថា គម្រោងសេវាសហគមន៍ ដែលត្រូវបានបង្កើតឡើងក្នុងអំឡុងឆ្នាំ២០០៤ ហើយនៅឆ្នាំ២០០៧ អង្គការមូលនិធិ ម៉េងលី ជេ. គួច បានបរិច្ចាគថវិកាចំនួន៥,០០០ដុល្លារដល់កាកបាតក្រហមកម្ពុជា ដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាជនក្រីក្រ និងគ្មានទីពឹង។ ចាប់តាំងពីបង្កើតគម្រោងនេះមក អង្គការមូលនិធិ ម៉េងលី ជេ. គួច បានផ្តល់ជំនួយឆ្លើយតបដល់អ្នកទទួលផលសរុបចំនួន ៦,០៧៤នាក់ ក្នុងនោះដូចជា ការផ្តល់គ្រឿងឧបភោគ បរិភោគ សម្លៀកបំពាក់ ថ្នាំសង្កូវ ដល់ស្ត្រីមេម៉ាយ កុមារកំព្រា និងចាស់ជរា។

នាចុងឆ្នាំ២០១៩ មូលនិធិ ម៉េងលី ជេ. គួច បានសិក្សា និងបានប្តូរឈ្មោះគម្រោងសេវាសហគមន៍ មកជាគម្រោងឆ្លើយតបសង្គ្រោះបន្ទាន់ ដែលស្ថិតនៅក្រោមកម្មវិធីសេវាសហគមន៍ ដែលត្រូវបានអនុម័តដោយឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី ជានាយកប្រតិបត្តិ នៃអង្គការមូលនិធិ ម៉េងលី ជេ. គួច នាថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៩។ កន្លងមក គម្រោងនេះបានឆ្លើយតបការសង្គ្រោះបន្ទាន់ជាច្រើន ដូចជាការផ្តល់ស្បៀងអាហារ និងសម្ភារចាំបាច់ដល់គ្រួសារក្រីក្រ ដែលកំពុងអត់ឃ្លាន និងការផ្តល់អាហារប្រចាំខែដល់សិស្សក្រីក្រផងដែរ។

01 អង្គការមូលនិធិ ម៉េងលី ជេ. គួច បរិច្ចាគថវិកា និងគ្រឿងឧបភោគបរិភោគដល់ប្រជាពលរដ្ឋក្រីក្រចំនួន១០៦គ្រួសារ សម្រាប់ទ្រទ្រង់ជីវភាពរបស់នៅរបស់ពួកគេ

02 អង្គការមូលនិធិ ម៉េងលី ជេ. គួច បរិច្ចាគថវិកាប្រចាំខែដល់ប្រជាពលរដ្ឋក្រីក្រចំនួន១០នាក់ ដែលជាស្ត្រីមេម៉ាយ ចាស់ជរា និងជនពិការ ដើម្បីរួមចំណែកសម្រួលជីវភាពរស់នៅប្រចាំថ្ងៃ



# គម្រោង ធនាគារអាហារសប្បុរសធម៌ ម៉េងលី ជេ. គួច

មូលនិធិ ម៉េងលី ជេ. គួច បានផ្តើអនុវត្តគម្រោងធនាគារអាហារសប្បុរសធម៌ ម៉េងលី ជេ. គួច លើកទី១ ដោយបានបរិច្ចាគអាហារដល់កុមារ១០០នាក់នៅមណ្ឌលក្តីសង្ឃឹមថ្មីនៃកុមារកម្ពុជា នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨។ គម្រោងនេះមានគោលបំណងជួយដល់ប្រជាជនក្រីក្រនៅក្នុងប្រទេសកម្ពុជា និងដើម្បីលើកកម្ពស់នូវវប្បធម៌ចែករំលែកនៅក្នុងសហគមន៍ផងដែរ ដើម្បីឱ្យពួកគេទទួលបាននូវរបបអាហារប្រកបដោយអនាម័យ ស្អាត និងជីវជាតិគ្រប់គ្រាន់ ព្រមទាំងអប់រំពួកគេឱ្យយល់ដឹងពីអនាម័យ និងការបរិភោគប្រកបដោយឥរិយាបថត្រឹមត្រូវ។ តាមផែនការយុទ្ធសាស្ត្រ គម្រោងធនាគារអាហារសប្បុរសធម៌ ម៉េងលី ជេ. គួច ត្រូវបានធ្វើជាប្រចាំ យ៉ាងហោចណាស់១ដងក្នុង១ខែ ជាពិសេសនៅរៀងរាល់ថ្ងៃសីល។ ចាប់តាំងពីកកើតគម្រោងនេះមក អង្គការមូលនិធិ ម៉េងលី ជេ. គួច បានធ្វើគម្រោងនេះបានចំនួន ២៥៨ លើកមកហើយ ដោយមានអ្នកទទួលផលសរុបចំនួន៤១៣៥,៣៧១គ្រួសារមកហើយ។

## សង្ខេបសមិទ្ធផល២០២១

- ឆ្លើយតបការរីករាលដាលជំងឺកូវីដ-១៩ក្នុងសហគមន៍ អង្គការមូលនិធិ ម៉េងលី ជេ. គួច បរិច្ចាគគ្រឿងឧបភោគបរិភោគមានដូចជាអង្ករ មី ទឹកស៊ីអ៊ីវ ទឹកត្រី ត្រីខកំប៉ុង និងម៉ាស ដល់ប្រជាពលរដ្ឋក្រីក្រចំនួន១,៤៤៧គ្រួសារ នៅក្នុងរាជធានីភ្នំពេញ ខេត្តត្បូងឃ្មុំ និងខេត្តកណ្តាល

- អង្គការមូលនិធិ ម៉េងលី ជេ. គួច បរិច្ចាគបបរគ្រឿងដ៏មានរសជាតិឆ្ងាញ់ និងសម្ភារសិក្សា ដល់កុមារកំព្រាចំនួន៦៦នាក់ ដែលកំពុងរស់នៅក្នុងសមាគមស្នាមញញឹមថ្មី នៃក្តីសង្ឃឹមកុមារ ស្ថិតក្នុងខេត្តកណ្តាល



# របាយការណ៍ហិរញ្ញវត្ថុ

អង្គការមូលនិធិ ម៉េងលី ជេ. គួច ក្នុងឆ្នាំ២០២១ បានចំណាយថវិកាប្រមាណ៨២,៤៥៩.៥៦ ដុល្លារអាមេរិក សម្រាប់ប្រតិបត្តិសកម្មភាពរបស់ខ្លួន និងការចំណាយរដ្ឋបាលក្នុងអង្គភាព ហើយថវិកាសម្រាប់ការចំណាយទាំងអស់នោះគឺទទួលបានប្រមាណ៥០%ពីក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ខណៈ៥០%ផ្សេងទៀតគឺបានពីការបរិច្ចាគថវិការបស់ Q&Q។

តែទោះជាយ៉ាងក៏ដោយ ដើម្បីធានានិរន្តរភាព និងលំនឹងហិរញ្ញវត្ថុរបស់ខ្លួន អង្គការមូលនិធិ ម៉េងលី ជេ. បានសហការជាមួយលោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងផ្នែកផ្សេងៗ នៃក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ដើម្បីបង្កើតគំនិតផ្តួចផ្តើមថ្មីៗក្នុងរៃអង្គាសថវិកាដើម្បីទទួលបានចំណូលបន្ថែម។ ក្នុងឆ្នាំ២០២១នេះ អង្គការមូលនិធិ ម៉េងលី ជេ. គួច ទទួលជំនួយសប្បុរសធម៌ និងថវិការៃអង្គាសបានសរុបចំនួន១៣១,១៥៤.៩៣ដុល្លារអាមេរិក។







## កន្លែងយើងធ្វើការ

យើងបានកំពុងប្រតិបត្តិការសកម្មភាពនៃកម្មវិធិទាំង៤ ក្នុងខេត្តក្រុងចំនួន២៤ ក្នុងព្រះរាជាណាចក្រកម្ពុជា រួមមានរាជធានីភ្នំពេញ ខេត្តកំពង់ចាម កណ្តាល តាកែវ កំពត កែប ស្វាយរៀង ព្រៃវែង កំពង់ស្ពឺ កោះកុង ព្រះសីហនុ ត្បូងឃ្មុំ បាត់ដំបង ក្រចេះ ពោធិ៍សាត់ សៀមរាប បន្ទាយមានជ័យ ឧត្តមានជ័យ ព្រះវិហារ ស្ទឹងត្រែង កំពង់ធំ កំពង់ឆ្នាំង និងខេត្តរតនៈគិរី។


Mengly J. Quach Foundation
A Mengly J. Quach Education



Join Together with Mengly J. Quach Foundation for Social and Charity Work!

Donate Now:

ACLEDA Bank Account's name: Mengly J. Quach Foundation, Account Number: #3473-0199-7997-27 (for Khmer riel)

ACLEDA Bank Account's name: Mengly J. Quach Foundation, Account Number: #3473-0199-7997-17 (for US dollar)

ABA Bank Account's name: Mengly J. Quach Education Plc, Account Number: #001082097

MJQ Foundation
MJQ Foundation Official
www.mjqfoundation.org
095 888 084

# ដៃគូរបស់យើង

អង្គការមូលនិធិ ម៉េងលី ជេ. គួច កំពុងធ្វើការក្នុងភាពជាដៃគូរយ៉ាងជិតស្និទ្ធជាមួយក្រសួងនានានៃព្រះរាជាណាចក្រកម្ពុជា ដូចជាក្រសួងអប់រំ យុវជន និងកីឡារ ក្រសួងសុខាភិបាល និងទីស្ដីការគណៈរដ្ឋមន្ត្រី ក្រុមហ៊ុន អង្គការជាតិ និងអន្តរជាតិ និងគ្រឹះស្ថានអប់រំនានាក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ។

MJQ Mengly J. Quach Education

Aii

AIS

MJQ TV

The Intercon Rooster

Mengly J. Quach University Press

Intercon Bookstore

ITS Intercon transportation services A Mengly J. Quach Education

PF ប្រសិទ្ធភាពហ្វាយនែន Prasethpheap Finance

GGEAR GROUP

JTI Japan Tobacco International

Monument Books

# ក្រុមប្រឹក្សាភិបាលរបស់យើង

ក្រុមប្រឹក្សាភិបាលរបស់អង្គការមូលនិធិ ម៉េងលី ជេ. គួច មានសមាសភាពចំនួន៩រូប មានប្រធាន១រូប អនុប្រធាន១រូប និងសមាជិកយ៉ាងច្រើន៧រូប ដោយមានអាណត្តិ៥ឆ្នាំ ហើយនៅពេលបញ្ចប់អាណត្តិនីមួយៗ សមាជិកក្រុមប្រឹក្សាភិបាលចាស់ មានសិទ្ធិឈរឈ្មោះធ្វើជាក្រុមប្រឹក្សាភិបាលក្នុងអាណត្តិបន្តបន្ទាប់ទៀតបាន។ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវដឹកនាំ និងតម្រង់ទិសសកម្មភាពរបស់មូលនិធិ និងត្រួតពិនិត្យប្រតិបត្តិការហិរញ្ញវត្ថុរបស់ខ្លួន។ ក្រុមប្រឹក្សាភិបាលក៏ទទួលខុសត្រូវក្នុងការអនុវត្ត និងលើកកម្ពស់គោលនយោបាយរបស់មូលនិធិ ហើយព្រមទាំងការអនុម័តជ្រើសរើសសមាជិកក្រុមប្រឹក្សាថ្មីផងដែរ។



**លោក គួច ផល**
ប្រធានក្រុមប្រឹក្សាភិបាល



**អ្នកឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី**
អនុប្រធានក្រុមប្រឹក្សាភិបាល



**លោក គួច អានឡិច**
សមាជិក



**លោក ចូវ ឌុទ្ធី**
សមាជិក



**លោក សួន ចន្ថាត**
សមាជិក



**លោក ហាន្ស ពិសិដ្ឋ**
សមាជិក



**លោក សាយ តិរម្យ**
សមាជិក



**កញ្ញា ស្រេន លាភា**
សមាជិក



**លោក វន្ស សុវណ្ណារ័ត្ន**
សមាជិក

# គណៈកម្មការប្រតិបត្តិរបស់យើង

គណៈកម្មការប្រតិបត្តិមានតួនាទីដឹកនាំ និងប្រតិបត្តិការងារគ្រប់គ្រងទូទៅក្នុងអង្គការមូលនិធិ ម៉េងលី ជេ. គួច។ ការជ្រើសរើសសមាជិកគណៈកម្មការប្រតិបត្តិ ត្រូវបានធ្វើឡើងដោយគណៈកម្មការប្រតិបត្តិអង្គការមូលនិធិ ម៉េងលី ជេ. គួច លើកលែងតែនាយកប្រតិបត្តិអង្គការ ត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សាភិបាលអង្គការមូលនិធិ ម៉េងលី ជេ. គួច។ សមាសភាពរបស់គណៈកម្មការប្រតិបត្តិនៃអង្គការមូលនិធិ ម៉េងលី ជេ. គួច មានសមាសភាពមួយចំនួនតាមការចាំបាច់ ដែលដឹកនាំដោយប្រធាន១រូបជានាយកប្រតិបត្តិអង្គការ។



**អ្នកឧកញ៉ា បណ្ឌិត គួច ម៉េងលី**

នាយកប្រតិបត្តិ



**លោក សែម សំអាន**

ប្រធានគ្រប់គ្រងកម្មវិធី



**លោក យ៉េង សូរិយ៉ា**

មន្ត្រីកម្មវិធី



**កញ្ញា ប៉ូ ចន្ថន**

អ្នកសម្របសម្រួលគម្រោង

# អក្សរកាត់៖

| ពាក្យកាត់ | ពាក្យពេញ |
|---|---|
| BoDs | Board of Directors |
| CCC | Cooperation Committee for Cambodia |
| CICAH | Cambodian Institute of Child and Adolescent Health |
| CSR | Corporate Social Responsibility |
| ED | Executive Director |
| GGEAR | Geriatrics and Gerontology Education and Research |
| GIK | Gift In Kind |
| IB | Intercon Book Store |
| ITD | Information Technology Development |
| MJQE | Mengly J. Quach Education |
| MJQF | Mengly J. Quach Foundation |
| MJQTV | Mengly J. Quach Televion |
| Q & Q | Quach and Quach |
| NGO | Non Government Organization |

# ទំនាក់ទំនង

## ការិយាល័យកណ្តាល៖

ផ្ទះលេខ២៥ABCD ផ្លូវលេខ ៤០២
សង្កាត់ទំនប់ទឹក ខណ្ឌចំការមន
ភ្នំពេញ កម្ពុជា

## ទំនាក់ទំនងព័ត៌មានទូទៅ៖

អ៊ីម៉ែល ៖ info@mjqfoundation.org
លេខទូរសព្ទ ៖ +855 95 888 084
គេហទំព័រ ៖ www.mjqfoundation.org

MJQ Foundation

MJQ Foundation Official

អង្គការមូលនិធិ ម៉េងលី ជេ. គួច
Mengly J. Quach
Foundation Organization

